**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ល.ក/លេខ ០៥.០២៥/១៣ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី 10 ខែឧសភា ឆ្នាំ២០១៣

## គ.ជ.ប បានទទួលជំនួយជាទឹកខ្មៅលុបលាងមិនជ្រះចំនួន 40,000ដប ពីប្រទេសឥណ្ឌា

យោងតាមលិខិតជាភាសាអង់គ្លេសចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ដែលមានចុះហត្ថលេខាដោយ ឯកឧត្តម **Dinesk k. Patnaik** (ឌីណេស ប៉ាតណៃក) ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបាន ឱ្យដឹងថា រដ្ឋាភិបាលនៃប្រទេសឥណ្ឌា នឹងផ្ដល់ជំនួយជាទឹកខ្មៅលុបលាងមិនជ្រះចំនួន **40,000**ដប ដល់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិ កាលទី៥ នាថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។

តាមលិខិតខាងលើបានសរសេរថា ទឹកខ្មៅលុបលាងមិនជ្រះចំនួន **40,000**ដប មានតម្លៃក្នុងរង្វង់ **45** លាន រូពី(ប្រមាណ **83** ម៉ឺនដុល្លារអាមេរិក) នឹងបញ្ជូនតាមយន្តហោះមកដល់រាជធានីភ្នំពេញ ក្នុងអំឡុងពាក់កណ្ដាល ខែមិថុនាខាងមុខនេះ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា រាល់ការបោះឆ្នោតនៅកម្ពុជាតាំង ពីការបោះឆ្នោតជាតិឆ្នាំ១៩៩៨ មក គ.ជ.ប បានបញ្ជាទិញ និងប្រើប្រាស់តែទឹកខ្មៅលុបលាងមិនជ្រះពីប្រទេស ឥណ្ឌាតែប៉ុណ្ណោះ ពីព្រោះវាមានគុណភាពលុបលាងមិនជ្រះក្នុងរយៈពេល ៧ទៅ១៥ថ្ងៃ ។ ឯកឧត្តមបាន បញ្ជាក់ថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ប្រទេសឥណ្ឌានឹងផ្ដល់ជាជំនួយនូវ ទឹកខ្មៅលុបលាងមិនជ្រះនេះ ហើយ គ.ជ.ប ក៏បានចេញលិខិតថ្លែងអំណរគុណមួយដល់រដ្ឋាភិបាលនៃប្រទេស ឥណ្ឌាផងដែរ ។

ទំនាក់ទំនងព័ត៌មាន ៖ ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ ;E-mail: necinfo@forum.org.kh ; www.necelect.org.kh